ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះនឹងបើកសវនាការស្តាប់អំណះអំណាងរបស់ភាគីនៅក្នុងសំណុំរឿង ០០៤/០១

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ២២ ខែ កុម្ភៈ និងថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

អង្គបុរេជំនុំជម្រះបានសម្រេចរៀបចំបើកសវនាការក្នុងសំណុំរឿង០០៤/០១ ដើម្បីស្តាប់អំណះអំណាងរបស់ភាគី មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នោះ។ អនុលោមតាមដីកាកំណត់កាលបរិច្ឆេទរៀបចំសវនាការដែលបានចេញនៅថ្ងៃនេះ សវនាការនោះនឹងរៀបចំធ្វើនៅថ្ងៃទី ១១ និងទី១២ ខែ ធ្នូ ឆ្នាំ ២០១៧។ ដីកាកំណត់កាលបរិច្ឆេទរៀបចំសវនាការជាសំណៅកោសលុបសម្រាប់សាធារណជនអាចរកបាននៅ
(https://www.eccc.gov.kh/document/court/39939)។

អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ ព្រមទាំងសហមេធាវីការពារក្តីជាតិ និងអន្តរជាតិ ធ្វើបទបង្ហាញអំពីអំណះអំណាងរបស់ខ្លួន។ ប្រសិនបើជនត្រូវចោទមានវត្តមាន គាត់នឹងទទួលបានឱកាសក្នុងការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់ផងដែរនៅពេលបញ្ចប់សវនាការ។

នៅពេលបញ្ចប់សវនាការ អង្គបុរេជំនុំជម្រះនឹងលើកពេលសវនាការដើម្បីពិភាក្សាចេញសេចក្តីសម្រេចរបស់ខ្លួន ថាតើនឹងច្រានចោលសំណុំរឿងនេះ ឬបញ្ជូនទៅជំនុំជម្រះ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រំពឹងថានឹងអាចចេញក្នុងរយៈពេលយ៉ាងយូរបំផុត ៦ ខែ ក្រោយពេលសវនាការ។

អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក រួមមានចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប។ ក្នុងឋានៈជាអង្គជំនុំជម្រះសម្រេចលើបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះអាចបើកសវនាការស្តាប់សំណើ និងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា និងសេចក្តីសម្រេចនានាដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ រាល់សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះតម្រូវឲ្យមានសម្លេងគាំទ្រពីចៅក្រម ៤ (បួន) រូបយ៉ាងតិច ក្នុងចំណោមចៅក្រមទាំងប្រាំរូប។

ដោយសារការស៊ើបអង្កេតត្រូវបានធ្វើឡើងជាសម្ងាត់ អង្គបុរេជំនុំជម្រះនឹងស្តាប់អំណះអំណាងរបស់ភាគីនៅក្នុងសវនាការជាអសាធារណៈ ប៉ុន្តែសាធារណជននឹងត្រូវបានអនុញ្ញាតឲ្យចូលរួមបាន នៅពេលភាគីណែនាំខ្លួនជូនអង្គជំនុំជម្រះ។ រូបថតផ្លូវការនឹងផ្តល់ជូនបណ្តាញសារព័ត៌មាន ក្រោយពេលសវនាការ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោកស្រី ហាយ៉ាត់ អាបូសាឡេស
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ៩៣៦
អ៊ីមែល៖ abusaleh@un.org

លោក ឌីម សុវណ្ណារុំ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៥១៨ ៤៨៥
អ៊ីមែល៖ dim.sovannarom@eccc.gov.kh